**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៩៣៩ **អយក.**ហ

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** សំណើសុំបន្ថែមវិសាលភាពលើអនុគណនីមួយចំនួន ដើម្បីរៀបចំបង្កើតរដ្ឋទេយ្យបុរេប្រទានសម្រាប់ការអនុវត្តថវិកាចាប់ពីឆ្នាំ២០២១ តទៅ នៅក្រសួងអប់រំ យុវជន និងកីឡា។

**យោង ៖** ប្រកាសលេខ៦៦៣ សហវ.ហក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានទទួលប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ព្រមទាំងបានប្រជុំណែនាំនិងផ្សព្វផ្សាយជូនគ្រប់អង្គភាពក្រោមឱវាទក្រសួងឱ្យយល់កាន់តែច្បាស់លាស់ អំពីការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ដើម្បីចូលរួមលើកកម្ពស់សុខុមាលភាពនៃការប្រើប្រាស់ថវិកាឱ្យចំទិសដៅ មានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យឃើញថា ក្នុងតារាងឧបសម្ព័ន្ធទី១នៃប្រកាសនេះ មិនបានបញ្ចូលនូវអនុគណនីមួយចំនួនដែលចាំបាច់និងអាទិភាពបំផុតសម្រាប់បង្កើតរដ្ឋទេយ្យបុរេប្រទាន ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់កិច្ចដំណើរការអង្គភាពជាប្រក្រតី និងជះឥទ្ធិពលដល់សកម្មភាពប្រតិបត្តិជាក់ស្តែងរបស់និស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ដូចនេះ ក្រសួង ស្នើសុំអនុញ្ញាតជាគោលការណ៍ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបន្ថែមវិសាលភាពលើអនុគណនីមួយចំនួន ដើម្បីជានាប្រសិទ្ធភាពដល់ការអនុវត្តថវិកាចាប់ពីឆ្នាំ២០២១ ឱ្យប្រព្រឹត្តទៅដោយរលូននិងទាន់ពេលវេលា រួមមាន៖

**១-ជំពូក៦០ (ការទិញ)៖**

-គណនី៦០០១ (សម្ភារផ្គត់ផ្គង់ថែទាំ) អនុគណនី៦០០១៥ (ប្រេងឥន្ធនៈនិងប្រេងរំអិល)
-គណនី៦០០៣ (ស្បៀងអាហារនិងផលិតផលកសិកម្ម) អនុគណនី៦០០៣២ (ចំណីសត្វ)
-គណនី៦០០៣ (ស្បៀងអាហារនិងផលិតផលកសិកម្ម) អនុគណនី៦០០៣៣ (ពូជនិងកូនរុក្ខជាតិ)



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

-គណនី៦០០៣ (ស្បៀងអាហារនិងផលិតផលកសិកម្ម) អនុគណនី៦០០៣៤ (ផលិតផលការពារសុខុមាលភាពរុក្ខជាតិនិងដី)

-គណនី៦០០៣ (ស្បៀងអាហារនិងផលិតផលកសិកម្ម) អនុគណនី៦០០៣៥ (ពូជសត្វ)

-គណនី៦០០៣(ស្បៀងអាហារនិងផលិតផលកសិកម្ម) អនុគណនី៦០០៣៦ (ឱសថនិងវត្ថុធាតុសម្រាប់បសុពេទ្យ)។

**២-ជំពូក៦១ (សេវាកម្ម)៖**

-គណនី៦១០៥ (ការថែទាំ និងជួសជុល) អនុគណនី៦១០៥២ (ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ)

-គណនី៦១១០ (ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ) អនុគណនី៦១១០៣ (ប្រជុំ សិក្ខាសាលា និងសន្និសីទ)

-គណនី៦១១២ (សោហ៊ុយបេសកកម្មក្នុងប្រទេស) អនុគណនី៦១១២១ (សោហ៊ុយដឹកជញ្ជូន)

-គណនី៦១១២ (សោហ៊ុយបេសកកម្មក្នុងប្រទេស) អនុគណនី៦១១២២ (សោហ៊ុយបេសកកម្ម)

-គណនី៦១១២ (សោហ៊ុយបេសកកម្មក្នុងប្រទេស) អនុគណនី៦១១២៣ (សោហ៊ុយស្នាក់នៅ)

-គណនី៦១១៣ (សោហ៊ុយបេសកកម្មក្រៅប្រទេស) អនុគណនី៦១១៣១ (សោហ៊ុយដឹកជញ្ជូន)

-គណនី៦១១៣ (សោហ៊ុយបេសកកម្មក្រៅប្រទេស) អនុគណនី៦១១៣២ (សោហ៊ុយបេសកកម្ម)

-គណនី៦១១៣ (សោហ៊ុយបេសកកម្មក្រៅប្រទេស) អនុគណនី៦១១៣៣ (សោហ៊ុយស្នាក់នៅ)។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពនិងអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានបន្ថែមវិសាលភាពលើអនុគណនីមួយចំនួនខាងលើ ដើម្បីរៀបចំបង្កើតរដ្ឋទេយ្យបុរេប្រទានសម្រាប់ការអនុវត្តថវិកាចាប់ពីឆ្នាំ២០២១តទៅ ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ថ្ងៃ ច័ន្ទ ៧កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**ចម្លងជូន៖**

-អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

" ដើម្បីជ្រាបជាព័ត៌មាន "

-កាលប្បវត្តិ

-ឯកសារ.នាយកដ្ឋានហិរញ្ញវត្ថុ